ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens


## ប្រធានអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
## ជំរាបមក
## លោកប្រធានអង្គការ Open Society Justice Initiative

**កម្មវត្ថុ** : សំណើធ្វើការកែតម្រូវលើសេចក្តីថ្លែងការណ៍កាលពីថ្ងៃទី ១៤ ខែ ០២ ឆ្នាំ ២០០៧

**យោង** : លទ្ធផលនៃកិច្ចប្រជុំរវាងចៅក្រមជាតិទាំងអស់ កាលពីថ្ងៃទី ០១ និង ០២ ខែ ០៣ ឆ្នាំ ២០០៧

តាមកម្មវត្ថុ និង យោងខាងលើ យើងខ្ញុំតាងនាមអោយចៅក្រមជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាំងអស់ មានការសោកស្តាយជាខ្លាំង ចំពោះ អង្គការ Open Society Justice Initiative ដែលបានចេញសេចក្តីថ្លែងការណ៍កាលពីថ្ងៃ ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៧ ធ្វើការចោទប្រកាន់ថា "ចៅក្រមកម្ពុជា ត្រូវធ្វើការកាត់ប្រាក់មួយចំណែកនៃប្រាក់បៀវត្សន៍របស់ខ្លួនជូនមន្ត្រីរដ្ឋាភិបាល ជាថ្នូរទៅនឹងមុខតំណែងរបស់ខ្លួននៅក្នុង អង្គជំនុំជម្រះ-វិសាមញ្ញក្នុងតុលាការកម្ពុជា" ។ ការចោទប្រកាន់ នេះគ្មានការពិតទាល់តែសោះ ហើយកន្លងមក ត្រូវបានសារពតិមានជាតិ និងអន្តរជាតិមួយចំនួន ធ្វើការផ្សព្វផ្សាយបន្តធ្វើអោយសាធារណៈជនមានការភ័ន្តច្រឡំ និង បានធ្វើអោយមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ កិត្តិយស និង ភាពសុចរិត របស់ចៅក្រមជាតិទាំងអស់ដែលត្រូវបានតែងតាំងអោយបំពេញភារកិច្ចនៅអង្គជំនុំជម្រះវិសាមញ្ញ ។

ចៅក្រមជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាំងអស់តាមរយៈនេះ សូមធ្វើការបញ្ជាក់ចំពោះលោកប្រធានព្រមទាំងសាធារណៈជនទាំងអស់ថា សេចក្តីសំរេចចិត្តរបស់យើងខ្ញុំ ក្នុងការទទួលយកតួនាទីបំរើការងារនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនបានធ្វើឡើងដោយស្ថិតនៅក្រោមចំណុះនៃសំពាធ រឺ លក្ខខ័ណ្ឌជាការសន្យាណាមួយដូចដែលបានចោទប្រកាន់នោះឡើយ ។ យើងខ្ញុំយល់ច្បាស់ណាស់ថាការរកយុត្តិធម៌ជូនប្រជាជនកម្ពុជាជាពិសេសជនរងគ្រោះពីរបបខ្មែរក្រហម គឺជាបេសកកម្មមួយដែលត្រូវបំពេញប្រកបដោយការទទួលខុសត្រូវខ្ពស់បំផុតក្នុងវិជ្ជាជីវៈជាចៅក្រម ។

អាស្រ័យហេតុនេះ សូមលោកធ្វើការកែតម្រូវសេចក្តីថ្លែងការណ៍ដែលបានចោទប្រកាន់មកលើចៅក្រមកម្ពុជាដោយ ពុំត្រឹមត្រូវនេះ តាមមធ្យោបាយសមស្រប ។

ធ្វើនៅទីក្រុងភ្នំពេញ ថ្ងៃទី ៨ ខែ ០៣ ឆ្នាំ ២០០៧

គង់ ស្រ៊ឹម